# កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានឈានដល់កិច្ចព្រមព្រៀងមួយមុននឹងឈានទៅបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីខុក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជា-ធិបតេយ្យ ។ កិច្ចព្រមព្រៀងជាប្រវត្តិសាស្ត្រនេះធ្វើឡើងនៅទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី១៣ដល់១៧ ខែមីនា ឆ្នាំ២០០៣ រវាងលោកអគ្គលេខាធិការរងអង្គការសហប្រជាជាតិ ហេន កូរែល និងឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានក្រុមការងាររៀបចំសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេសនិងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ការទម្ពុះភាពទ័លច្រកដែលមតិភាគច្រើនមិនដែលរំពឹងថានឹងអាចកើតមានឡើងនោះគឺជាលទ្ធផលនៃការចរចាចំនួន១១លើក និងប្រើរយៈពេលជាងប្រាំឆ្នាំគិតចាប់ពីឆ្នាំ១៩៩៧-៩៨មកដល់ឆ្នាំ២០០៣ ហើយកិច្ចចរចាគំហុកចុងក្រោយនេះគឺធ្វើឡើងតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិដែលផ្តល់អាណត្តិដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបន្តការចរចាក្រោយពេលអង្គការសហប្រជាជាតិបានដកថយនៅខែកុម្ភៈ ឆ្នាំ២០០២ ។

សេចក្តីព្រាងថ្មីនេះមាន៣២មាត្រា ហើយទទួលស្គាល់យុត្តាធិការទៅលើសាច់រឿងដែលជាប់វិវាទនិងយុត្តាធិការទៅលើរូបបុគ្គលដូចដែលចែងនៅក្នុងច្បាប់ស្តីអំពី “ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីខុក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ” ដែលមាន១៨ជំពូក និង៤៨មាត្រា ។ សេចក្តីព្រាងកិច្ចព្រមព្រៀងនេះគ្រប់គ្រងតាមច្បាប់ទៅលើកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម រួមទាំងបញ្ហាបច្ចេកទេស រដ្ឋបាល ការស៊ើបអង្កេត ការតែងតាំង ការប្រើភាសាក្នុងតុលាការ ការលើកលែងទោស ការរកដំណោះស្រាយនៅពេលគ្មានមតិឯកច្ឆន្ទក្នុងការសម្រេចចិត្ត ជាពិសេសបញ្ហាថវិកានិងជំនួយផ្សេងៗរបស់អង្គការសហប្រជាជាតិផង ។ បញ្ហាសំខាន់មួយទៀតគឺ នៅមាត្រា២៨ ដែលចែងពីការរក្សាសិទ្ធិដកថយពីដំណើរការជំនុំជម្រះ ប្រសិនបើមានបញ្ហាបច្ចេកទេសផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងដែលអង្គការសហប្រជាជាតិយល់ថានឹងប្រាសចាកពីកិច្ចព្រមព្រៀងនេះ ។ “ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធ ឬអង្គការលេខនៃអង្គជំនុំជម្រះវិសាមញ្ញឬធ្វើអ្វីផ្សេងពីនេះដែលជាហេតុបង្កឲ្យអង្គជំនុំជម្រះមិនអាចធ្វើបំពេញតួនាទីទៅតាមកិច្ចព្រមព្រៀង បច្ចុប្បន្ននេះអង្គការសហប្រជាជាតិរក្សាសិទ្ធិឈប់ផ្តល់ជំនួយ ទោះជំនួយជាថវិកា ឬជំនួយផ្សេងៗទៀតដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ” ។ ចំណុចសំខាន់ចុងក្រោយមួយទៀតគឺ ការបញ្ជាក់បន្ថែមនូវមាត្រា២៦និង២៧នៃអនុសញ្ញាទីក្រុងវីយែន ស្តីអំពីច្បាប់នៃសន្ធិសញ្ញា ។ តាមខ្លឹមសារនៃមាត្រាទាំងពីរនេះគឺថា រាល់សន្ធិសញ្ញាដែលនៅជាធរមានគឺតម្រូវឲ្យភាគីនៃសន្ធិសញ្ញាត្រូវតែអនុវត្តដោយសុទ្ធចិត្ត ហើយភាគីនោះមិនត្រូវអនុវត្តបទបញ្ញត្តិក្នុងស្រុក ដោយលើកហេតុផលថាខ្លួនមិនអាចអនុវត្តតាមបទបញ្ញត្តិនៅក្នុងអនុសញ្ញាអន្តរជាតិបានទេ ។ កម្ពុជាបានក្លាយជាភាគីហត្ថលេខីនៃអនុសញ្ញាទីក្រុងវីយែន នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៦៩ ។ បទបញ្ញត្តិជាច្រើននៃអនុសញ្ញានេះត្រូវបានទទួលស្គាល់ថាបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។

សេចក្តីព្រាងកិច្ចព្រមព្រៀងនេះនឹងត្រូវអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនិងសភាជាតិកម្ពុជា មុនពេលចាប់ផ្តើមដំណើរការអង្គជំនុំជម្រះក្តីវិសាមញ្ញនេះ ។ មេដឹកនាំខ្មែរក្រហមដែលនៅរស់មានដូចជា នួន ជា, ខៀវ សំផន, អៀង សារី, តាម៉ុក និង ឌុច ។

**សួ ប៊ុនស៊ី**